**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

លេខ ...................... .រ.ស.

# សេចក្តីថ្លែងការណ៍

អ្នកតំណាងរាស្ត្រនៃគណបក្ស សម រង្ស៊ី សម្តែងការសោកស្តាយយ៉ាងខ្លាំងចំពោះការបង្ក្រាបដោយហិង្សាពីសំណាក់កងកម្លាំងនគរបាល និងកងរាជអាវុធហត្ថ ទៅលើបងប្អូនកម្មករ-កម្មការិនី ដែលបណ្តាលឲ្យកម្មករ-កម្មការិនីជាច្រើនទទួលរងរបួស និងមួយចំនួនទៀតត្រូវបានចាប់ខ្លួន ខណៈដែលពួកគេធ្វើកូដកម្មនៅមុខរោងចក្រកាត់ដេរ **ជួនតិចថាយល៍** (*ហៅ* ***មិថុនា***) ដើម្បីទាមទារឲ្យថៅកែរោងចក្រ បើកប្រាក់អតីតភាពការងាររបស់ខ្លួន កាលពីព្រឹកថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១១ ។

ការចាប់ខ្លួន និងការប្រើអំពើហឹង្សាមកលើកូដករបែបនេះ គឺជាទង្វើរំលោភបំពានយ៉ាងធ្ងន់ធ្ងរមកលើសិទ្ធិមនុស្ស និងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់កម្មករ-កម្មការិនី ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីកូដកម្មដោយសន្តិវិធី របស់កម្មករ-កម្មការិនី ។

អ្នកតំណាងរាស្ត្រនៃគណបក្ស សម រង្ស៊ី សូមគាំទ្រចំពោះការធ្វើកូដកម្មដោយអហិង្សារបស់បងប្អូនកម្មករ-កម្មការិនី នៃរោងចក្រកាត់ដេរ **ជួនតិចថាយល៍** (*ហៅ* ***មិថុនា***) ដើម្បីទាមទារនូវប្រាក់អតីតភាពការងាររបស់ខ្លួន ស្របតាមលក្ខខ័ណ្ឌការងារនៃរោងចក្រ ។

ជាមួយគ្នានេះដែរ អ្នកតំណាងរាស្ត្រនៃគណបក្ស សម រង្ស៊ី សូមថ្កោលទោសចំពោះការចាប់ខ្លួន និងការប្រើអំពើហិង្សាមកលើបងប្អូនកម្មករ-កម្មការិនី នៃរោងចក្រកាត់ដេរ **ជួនតិចថាយល៍** (*ហៅ* ***មិថុនា***) ហើយសូមឲ្យអាជ្ញាធរដោះលែងតំណាងកម្មករ-កម្មការិនី កញ្ញា **ផេង ជួ** និងកញ្ញា **មាស សារិន** ឲ្យមានសេរីភាពឡើងវិញជាបន្ទាន់ និងសូមអំពាវនាវឲ្យស្ថាប័នមានសមត្ថកិច្ច ព្រមទាំងថៅកែរោងចក្រកាត់ដេរ **ជួនតិចថាយល៍** (*ហៅ* ***មិថុនា***) ធ្វើការដោះស្រាយនូវប្រាក់អតីតភាពការងារជូនដល់កម្មករ-កម្មការិនី តាមលក្ខខ័ណ្ឌ និងច្បាប់ការងារឲ្យបានសមរម្យ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១១*

**អ្នកតំណាងរាស្ត្រនៃគណបក្ស សម រង្ស៊ី**

*ព័ត៌មានបន្ថែម សូមទំនាក់ទំនង :*

*_លោក ហួរ វ៉ាន់ : ០១២ ៧៥៣ ៨៧៧*